**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងការបរទេស**
**និងសហប្រតិបត្តិការអន្តរជាតិ**
លេខ បព ២៨/២០២៥ កបទ.សអ

សេចក្តីប្រកាសព័ត៌មាន

# សម្តេចធិបតីនាយករដ្ឋមន្ត្រី ហ៊ុន ម៉ាណែត ជួបសម្តែងការគួរសមជាមួយ ឯកឧត្តម វ៉ាង ហូនីង ប្រធានសភាប្រឹក្សានយោបាយប្រជាជនចិន ក្នុងឱកាសចូលរួមកិច្ចប្រជុំកំពូលអង្គការសហប្រតិបត្តិការសៀងហៃប៉ូក

នៅថ្ងៃទី៣១ ខែសីហា ឆ្នាំ២០២៥ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានជួបសម្តែងការគួរសមជាមួយ **ឯកឧត្តម វ៉ាង ហូនីង** ប្រធានសភាប្រឹក្សានយោបាយប្រជាជនចិន ក្នុងឱកាសអញ្ជើញចូលរួមកិច្ចប្រជុំកំពូលនៃអង្គការសហប្រតិបត្តិការសៀងហៃប៉ូក ចាប់ពីថ្ងៃទី ៣១ សីហា ដល់ថ្ងៃទី ១ កញ្ញា ឆ្នាំ២០២៥ នៅទីក្រុងធានជីន នៃសាធារណរដ្ឋប្រជាមានិតចិន។

**សម្តេចធិបតីនាយករដ្ឋមន្ត្រី**បានថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះរដ្ឋាភិបាល និងប្រជាជនចិន ដែលបានផ្តល់កិច្ចស្វាគមន៍យ៉ាងកក់ក្តៅ និងបដិសណ្ឋារកិច្ចដ៏ល្អចំពោះគណៈប្រតិភូកម្ពុជា។ ថ្នាក់ដឹកនាំទាំងពីរបានសម្តែងនូវទំនុកចិត្តថា លទ្ធផលនៃជំនួបប្រកបដោយខ្លឹមសាររបស់ **សម្តេចធិបតី ហ៊ុន ម៉ាណែត** ជាមួយ **ឯកឧត្តមប្រធានាធិបតី ស៊ី ជីងពីង** កាលពីមួយថ្ងៃមុននេះ ព្រមទាំងការព្រមព្រៀងគ្នាជាឯកច្ឆន្ទក្នុងឱកាសដំណើរទស្សនកិច្ចជាប្រវត្តិសាស្ត្ររបស់ **ឯកឧត្តមប្រធានាធិបតីចិន** នៅប្រទេសកម្ពុជា កាលពីខែមេសាឆ្នាំនេះ នឹងធ្វើឱ្យកាន់តែស៊ីជម្រៅថែមទៀតនូវទំនាក់ទំនងមិត្តភាពដែកថែប និងភាពជាដៃគូយុទ្ធសាស្ត្រគ្រប់ជ្រុងជ្រោយ... 

ថ្នាក់ដឹកនាំទាំងពីរបានផ្លាស់ប្តូរយោបល់គ្នាផងដែរ អំពីស្ថានការណ៍នៅតាមបណ្តោយព្រំដែនកម្ពុជា-ថៃ។ **ឯកឧត្តម វ៉ាង ហូនីង** បានសម្តែងការគាំទ្រចំពោះការបង្កើនកិច្ចប្រឹងប្រែង ដើម្បីអនុវត្តឱ្យមានប្រសិទ្ធភាពនូវបទឈប់បាញ់ដែលបានព្រមព្រៀងគ្នា និងការរិះរកនូវដំណោះស្រាយដោយសន្តិវិធីចំពោះបញ្ហាព្រំដែន តាមរយៈយន្តការទ្វេភាគីដែលមានស្រាប់ ស្របតាមច្បាប់អន្តរជាតិ។ **សម្តេចធិបតីនាយករដ្ឋមន្ត្រី** បានថ្លែងជាថ្មីនូវអំណរគុណយ៉ាងស្មោះស្ម័គ្ររបស់កម្ពុជា ចំពោះរដ្ឋាភិបាល និងប្រជាជនចិន ដែលបានគាំទ្រយ៉ាងខ្ជាប់ខ្ជួនដល់កម្ពុជា ក្នុងការជំរុញកិច្ចអភិវឌ្ឍន៍សេដ្ឋកិច្ច-សង្គម ការពារសន្តិភាព ស្ថិរភាព និងឯករាជ្យជាតិ។

នៅថ្ងៃដដែលនេះដែរ **សម្តេចធិបតី ហ៊ុន ម៉ាណែត** ក៏បានជួប **ឯកឧត្តម ជិន លីគុណ** ប្រធានធនាគារវិនិយោគហេដ្ឋារចនាសម្ព័ន្ធអាស៊ី(AIIB)។ កិច្ចពិភាក្សាបានគ្របដណ្តប់លើលទ្ធភាពគម្រោងអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងសង្គមធំៗរបស់កម្ពុជា ដែលអាចប្រើប្រាស់ហិរញ្ញប្បទាន ក្រោមកម្មវិធីពហុឆ្នាំរបស់ធនាគារ AIIB។

ថ្ងៃអាទិត្យ ៨កើត ខែភទ្របទ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩
រាជធានីភ្នំពេញ ថ្ងៃទី៣១ ខែសីហា ឆ្នាំ២០២៥

អាសយដ្ឋាន: លេខ ៣ វិថី សម្តេច ហ៊ុន សែន
សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ : (855) 23 216 122
ទូរសារ: (855) 23 216 141, 023 213 341
អ៊ីម៉ែល: mfaic@mfaic.gov.kh